ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING

ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ
CAMBODIAN NATIONAL COUNCIL
FOR CHILDREN

លេខ : ១២៩ក.ជ.ក.ក

# សេចក្តីសំរេច
## ស្តីពី
## ការបង្កើតអនុគណៈកម្មការអភិវឌ្ឍកុមារតូច

## ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ៥៦ អនក្របក ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ
- យោងតាមប្រការ ៤ នៃអនុក្រឹត្យលេខ ៥៦ អនក្របក ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ១៩៩៩ និង យោងតាមតំរូវការចាំបាច់នាពេលបច្ចុប្បន្ន ។
- តាមស្មារតីអង្គប្រជុំនៅអង្គការ Unicef ចុះថ្ងៃទី ៥ ខែ មិថុនា ឆ្នាំ ២០០២

## សំរេច

<u>ប្រការ១</u> .-

បង្កើតអនុគណៈកម្មការអភិវឌ្ឍកុមារតូច សំរាប់ធ្វើការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីលើកកំពស់ការរស់រានការលូតលាស់ ការអភិវឌ្ឍន៍របស់កុមារ និង ការពារសិទ្ធិកុមារអោយមានសុខភាព អាហារូបត្ថម្ភ និង ការអភិវឌ្ឍន៍ជីវិតស្តង់ដាខ្ពស់បំផុត ដូចមានចែងក្នុងមាត្រា ៦ និង មាត្រា ២៤ នៃអនុសញ្ញា ស្តីពីសិទ្ធិកុមារ ។

ប្រការ ២ .-

សមាសភាពអនុគណៈកម្មការអភិវឌ្ឍកុមារតូច មានដូចខាងក្រោម :

| | |
|---|---|
| ១- ឯកឧត្តមអនុប្រធាន ក.ជ.ក.ក តំណាងក្រសួងសុខាភិបាល | ជាប្រធាន |
| ២- ឯកឧត្តមអនុប្រធាន ក.ជ.ក.ក តំណាងក្រសួងអប់រំ យុវជន និង កីឡា | ជាអនុប្រធាន |
| ៣- ប្រធានមជ្ឈមណ្ឌលជាតិគាំពារមាតា និង ទារក នៃក្រសួងសុខាភិបាល | ជាអនុប្រធានអចិន្ត្រៃយ៍ទី១ |
| ៤- ប្រធាននាយកដ្ឋានបឋម និង មត្តេយ្យសិក្សា នៃក្រសួងអប់រំ យុវជន និង កីឡា | ជាអនុប្រធានអចិន្ត្រៃយ៍ទី២ |
| ៥- មន្ត្រីតំណាងនាយកដ្ឋានសេដ្ឋកិច្ចសង្គម នៃក្រសួងផែនការ | ជាសមាជិក |
| ៦- មន្ត្រីតំណាងនាយកដ្ឋានថែទាំសុខភាពជនបទ នៃក្រសួងអភិវឌ្ឍន៍ជនបទ | ជាសមាជិក |
| ៧- មន្ត្រីតំណាងនាយកដ្ឋានសុខមាលភាពកុមារ នៃក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា | ជាសមាជិក |
| ៨- មន្ត្រីតំណាងនាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្ស នៃក្រសួងកិច្ចការនារី និង អតីតយុទ្ធជន | ជាសមាជិក |
| ៩- មន្ត្រីតំណាងនាយកដ្ឋានស្រាវជ្រាវជម្ងឺឆ្លង នៃក្រសួងសុខាភិបាល | ជាសមាជិក |
| ១០- នាយកកម្មវិធីអាហារូបត្ថម្ភនៃក្រសួងសុខាភិបាល | ជាសមាជិក |
| ១១- មន្ត្រីតំណាងនាយកដ្ឋានបណ្តុះបណ្តាល និង វិក្រឹតការ នៃក្រសួងអប់រំ | ជាសមាជិក |
| ១២- មន្ត្រីតំណាងនាយកដ្ឋានស្រាវជ្រាវ និង គរុកោសល្យ នៃក្រសួងអប់រំ | ជាសមាជិក |
| ១៣- មន្ត្រីតំណាងក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ | ជាសមាជិក |
| ១៤- មន្ត្រីតំណាងអង្គការយូនីសេហ្វ | ជាជំនួយការបច្ចេកទេស |
| ១៥- មន្ត្រីតំណាងអង្គការយូណេស្កូ | ជាជំនួយការបច្ចេកទេស |
| ១៦- មន្ត្រីតំណាងអង្គការសុខភាពពិភពលោក | ជាជំនួយការបច្ចេកទេស |

ប្រការ ៣ .-

អនុគណៈកម្មការអភិវឌ្ឍន៍កុមារតូច មានភារកិច្ចទទួលខុសត្រូវ ដូចតទៅ :

១- សហការជាមួយក្រសួងពាក់ព័ន្ធដើម្បីវាយតម្លៃសភាពការនិងរៀបចំគោលនយោបាយ និង យុទ្ធសាស្ត្រជាតិ ស្តីពីការអភិវឌ្ឍន៍កុមារតូច ។

២- ទាក់ទាញការគាំទ្រពីចំណោមអ្នកធ្វើគោលនយោបាយ អ្នកធ្វើសេចក្តីសំរេចចិត្ត និង អ្នកធ្វើផែនការ ដើម្បីគាំទ្រដល់ការអភិវឌ្ឍន៍ និង ការអនុវត្តន៍គោលនយោបាយជាតិ ស្តីពីការអភិវឌ្ឍន៍កុមារតូច ។